ស.អ.ក
សហព័ន្ធស្រូវអង្ករកម្ពុជា
CAMBODIA RICE FEDERATION

# របាយការណ៍សង្ខេបនៃការនាំចេញអង្ករកម្ពុជា រយៈពេល៨ខែ ឆ្នាំ២០២០ និងខែសីហា ឆ្នាំ២០២០

# Cambodia's Rice Export Summary Report 8 months of 2020 and August 2020

#2C, Street 120, Sangkat Phsar Tmey II, Khan Daun Penh, Phnom Penh, Cambodia
www.crf.org.kh    info@crf.org.kh    (855) 23 559 8999

## ការនាំចេញអង្កររបស់កម្ពុជា ក្នុងរយៈពេល ៨ខែ នៃឆ្នាំ២០២០ មានបរិមាណសរុបចំនួន ៤៤៨ ២០៣ តោន និងទទួលបានចំណូល ជិត ៣០០លានដុល្លារសហរដ្ឋអាមេរិក

ក្នុងរយៈពេល៨ខែ នៃឆ្នាំ២០២០ កម្ពុជាបានសម្រេចការនាំចេញ អង្ករគ្រប់ប្រភេទចំនួន ៤៤៨ ២០៣តោន ដែលមានកំណើន ជាង៣១% បើប្រៀបធៀបទៅរយៈពេលដូចគ្នាឆ្នាំ២០១៩ និង គិតជាទឹកប្រាក់ មានចំនួនសរុប ២៩៩.៩០ លានដុល្លារ សហរដ្ឋអាមេរិក។

## Cambodia's milled-indica rice export in 8 months of 2020 reached 448,203 tonnes, receiving about USD 300 million

In 8 months of 2020, Cambodia achieve the milled rice export in the total amount of 448,203 tonnes, increased by 31% comparing to the same period in 2019, and receiving USD 299.90 million as the gross revenue.

គោលដៅទីផ្សារនាំចេញអង្ករកម្ពុជា ក្នុងរយៈពេល៨ខែ ឆ្នាំ២០២០
Cambodian Rice Market  Desitnations in 8 months of 2020




បរិមាណនាំចេញអង្ករកម្ពុជា ៨ខែ ក្នុងឆ្នាំ២០២០ តាមទីផ្សារគោលដៅ ធៀបនឹងរយៈពេលដូចគ្នា ឆ្នាំ២០១៩
Cambodian Rice Export Destinations Statistic
8 months of 2020 VS 8 months of 2019




ក្នុងរយៈពេល៨ខែនេះ កម្ពុជាបាននាំចេញទៅកាន់ប្រទេសចិន បានចំនួន ១៥៩ ២៥៣តោន សហគមន៍អឺរ៉ុបបានចំនួន ១៤៩ ៨៤៨ តោន បណ្តាប្រទេសសមាជិកអាស៊ានបានចំនួន ៦០ ៩៣៣តោន ហើយនិងបណ្តាប្រទេសផ្សេងៗចំនួន ២៦ គោលដៅ រួមមាន ហ្គាប៊ុង អូស្ត្រាលី ជាដើម មានចំនួន ៧៨ ១៦៩ តោន។

China is the lead market, which the amount is 159,253 tonnes, European Union (EU including England) is 149,848 tonnes, ASEAN Members is 60,933 tonnes, and the rest (78,169 tonnes) to 26 destinations, mainly Gabon, Australia, and etc.

បរិមាណនាំចេញប្រភេទអង្ករគ្រាប់វែង( Indica rice ) នេះ បានធ្វើអោយកម្ពុជាមានចំណែក នៅក្នុងទីផ្សារសហគមន៍អឺរ៉ុបលំដាប់លេខពីរ បន្ទាប់ពីប្រទេសថៃ ដោយកាន់កាប់ចំណែកទីផ្សារ ២៤.៤% ខណៈប្រទេសថៃកាន់ចំណែក ២៩.៦% ហើយប្រទេសកម្ពុជាក៏ឈរជើងលំដាប់ទី៥ បន្ទាប់ពីវៀតណាម មីយ៉ាន់ម៉ា ប៉ាហ្គីស្ថាន និងប្រទេសថៃ ដោយកម្ពុជាមានចំណែកទីផ្សារ ប្រមាណជិត១១% នៃទីផ្សារអង្ករនាំចូលទៅកាន់ប្រទេសចិន លើប្រភេទអង្ករគ្រាប់វែង( Indica-Long grain ) បើទោះជាអង្ករកម្ពុជា ទើបឈានចូលទៅកាន់ទីផ្សារប្រទេសចិននៅក្នុងឆ្នាំ២០១១ក៏ដោយ តែបានទទួលនូវកំណើនយ៉ាងឆាប់រហ័ស ជាពិសេសប្រភេទអង្ករក្រអូបបានកើនជាង៨០% នៅឆ្នាំ២០១៩ ដែលកាលពីឆ្នាំ២០១៥ មានត្រឹមតែ ៤៥.៣% តែប៉ុណ្ណោះ ។

ទីផ្សារអង្ករកម្ពុជា ទៅកាន់ប្រទេសអូស្ត្រាលីកំពុងមានសន្ទុះយ៉ាងខ្លាំងផងដែរ ក្នុងរយៈពេល៨ខែ នៅក្នុង២ឆ្នាំចុងក្រោយនេះ ដែលកើនឡើងចំនួន ៩៤៦.២៧% ពោលគឺ ពី ១ ៩៩៩ តោន ក្នុងឆ្នាំ២០១៨ ទៅដល់ ២០ ៩១៥ តោន ក្នុងឆ្នាំ២០២០។

ប៉ុន្តែសម្រាប់ខែសីហាឆ្នាំ ២០២០ នេះ ការនាំចេញបានធ្លាក់ចុះប្រមាណជាង ៣៤% បើប្រៀបធៀបរយៈពេលដូចគ្នាទៅឆ្នាំ២០១៩។ ការធ្លាក់ចុះ ដែលជាពិសេសទៅលើអង្ករប្រភេទស្រូវសែនក្រអូប បានធ្លាក់ចុះ៨៥.៧៨% ដែលកាលពីខែសីហាឆ្នាំ២០១៩ ការនាំចេញបានរហូតទៅដល់ ១៦ ៣៨៦ តោន តែក្នុងខែសីហា ឆ្នាំ២០២០នេះបានត្រឹមតែ ២ ៣៣៨ តោនប៉ុណ្ណោះ។

Cambodian milled-indica rice is ranked as the second rice importer to European Union, capturing 24.4%, while Thai rice captured 29.6% of market shares. By the way, in the Chinese market, Cambodian milled-indica rice is also ranked fifth after Vietnam, Myanmar, Pakistan and Thailand, with nearly 11% of the market shares. Despite the recent entry of Cambodian rice to the Chinese market in 2011, it has seen rapid growth, especially fragrant rice, increased by more than 80% in 2019 from 45.3% in 2015.

For the same period of 8 months, Australia market is dramatically increased by 946.27%, from 1,999 tonnes in 2018 to 20,915 tonnes in 2020.

On the other hand, in August 2020, Cambodia’s milled rice export is dropped by more than 34%, comparing to the same period in 2019. The drop down volume, specifically on fragrant rice, is 85.7%, while in August 2019, the export reached 16,386 tonnes, but in this August 2020, achieved only 2,338 tonnes.



ការធ្លាក់ចុះនៃការនាំចេញស្រូវប្រាំង ជាពិសេសស្រូវសែនក្រអូបនេះ ដោយសារកត្តាចម្បងចំនួន២ រួមមាន៖

១.) កត្តាបម្រែបម្រួលអាកាសធាតុបានធ្វើឱ្យស្រូវប្រាំងដែលបានដាំដុះក្នុងខែឧសភា ហើយត្រូវប្រមូលផល នៅចុងខែកក្កដា និងសីហា បានខូចខាតមួយចំនួនធំ ហើយដោយសារគ្រោះរាំងស្ងួត (កូនរដូវប្រាំងក្នុងរដូវវស្សា នៅក្នុងខែមិថុនា និងសីហា) បានជំរុញឱ្យកសិករដាំដុះឡើងវិញ ជាពិសេសវាលស្រែដែលនៅឆ្ងាយពីប្រភពទឹក ហើយចំពោះស្រូវដែលត្រូវប្រមូលផលក្នុងបរិមាណមានកំណត់ បានជំរុញតម្លៃស្រូវឱ្យកើនឡើងប្រមាណជា២០%ផងដែរ បើប្រៀបធៀបរយៈពេលដូចគ្នាទៅឆ្នាំ ២០១៩។

២.) ការឈប់សំរាកសងពេលចូលឆ្នាំខ្មែរ ដែលលើកពីខែមេសា មកខែសីហានេះ បានធ្វើអោយការងាររដ្ឋបាល និងសេវាមួយចំនួន មានការយឺតយ៉ាវផងដែរ ជាពិសេសក្នុងសប្តាហ៍ទី៣ នៃខែសីហានេះតែម្តង។

**ការនាំចេញបានចាប់ផ្តើមប្រសើរឡើងវិញនៅសប្តាហ៍ទី៤នៃខែសីហា ហើយរំពឹងថា ការនាំចេញនឹងបានល្បឿនល្អចាប់ពីខែកញ្ញាតទៅ។**

The decline exports of fragrant rice (SKO) is due to two main factors, including:

1.) Climate change (drought) has delayed the harvesting and replanted to September. By the way the paddy price for the early harvest in August also increased by 20% compared to the same period in 2019.

2.) The long public holiday in the third week of August affected the export procedures and formalities.

**Exports resumed better in the fourth week of August and expected speeding from September.**

គោលដៅទីផ្សារនាំចេញអង្ករកម្ពុជា ក្នុងខែសីហា ឆ្នាំ២០២០
Cambodian Rice Market  Desitnations in August 2020

បរិមាណនាំចេញសរុប ៖ ២២ ១៣០ តោន

Total export: 22,130 Tonnes




## សហព័ន្ធស្រូវអង្ករកម្ពុជា (Cambodia Rice Federation)

ប្រធានក្រុមប្រឹក្សាភិបាល (Chairman) ៖ លោកឧកញ៉ា ហ៊ុន ឡាក់ (Oknha Hun Lak)
ប្រធានសហព័ន្ធ (President) ៖ លោកឧកញ៉ា សុង សារ៉ន (Okhna Song Saran)
អគ្គលេខាធិការ (Secretary General) ៖ លោក លន់ យ៉េង (Mr. Lun Yeng)

ដកស្រង់ និងវិភាគដោយ (Cited and Analysed by) ៖ លោក លន់ យ៉េង- អគ្គលេខាធិការ (Mr. Lun Yeng )
រចនាដោយ (Designed by) ៖ កញ្ញា សន ឆវីវតី - មន្ត្រីសម្របសម្រួលទំនាក់ទំនង (Ms. Sorn Chhorvyvatey - Communication Coordinator)

https://www.facebook.com/cambodiaricefederation/
www.crf.org.kh
https://twitter.com/RiceCrf
សហព័ន្ធស្រូវអង្ករកម្ពុជា Cambodia Rice Federation



ប្រភពទិន្នន័យ៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា Source: Ministry of Agriculture Forestry and Fisheries, and General Department of Customs and Excise